ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋសភា

# សេចក្តីថ្លែងការណ៍

**រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា** សម្តែងនូវការខកចិត្តយ៉ាងខ្លាំង ចំពោះការប្រកាសគាំទ្ររបស់ **ឯកឧត្តម វ៉ាន់មូហាម៉ាត់ ណ័រ មះថា** ប្រធានសភាតំណាងរាស្ត្រ និងជាប្រធានរដ្ឋសភាថៃ ចំពោះ **លោកឧត្តមសេនីយ៍ឯក ប៊ុនស៊ីន ផាត់ឃ្លាំង** មេបញ្ជាការយោធភូមិភាគទី២ របស់ថៃ ដែលបានចុះផ្សាយជាភាសាថៃនៅក្នុងគេហទំព័ររដ្ឋសភានៃព្រះរាជាណាចក្រថៃ និងកាសែត The Nation កាលពីថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៥ កន្លងទៅ ដែល **លោកឧត្តមសេនីយ៍ឯក ប៊ុនស៊ីន ផាត់ឃ្លាំង** បានប្រកាសពីផែនការមុនចូលនិវត្តន៍របស់ខ្លួន ដែលនៅសល់ ៥១ ថ្ងៃទៀត ដោយ ៖ ទី១) ដណ្តើមកាន់កាប់ប្រាសាទតាក្របី ពីការគ្រប់គ្រងដោយស្របច្បាប់របស់កម្ពុជា និង ទី២) ប្រកាសបិទប្រាសាទតាមាន់ធំដែលស្ថិតក្នុងដែនអធិបតេយ្យ និងបូរណភាពទឹកដីកម្ពុជា។ ការប្រកាសនេះជាភស្តុតាងជាក់ស្តែង និងមិនអាចប្រកែកបាន បញ្ជាក់ពីការបង្កហេតុ និងជាការប៉ុនប៉ងឈ្លានពានទឹកដីកម្ពុជាដោយចេតនា និងដោយគិតទុកជាមុន។

**រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា** ចាត់ទុកការសម្តែងមតិគាំទ្ររបស់ **ឯកឧត្តម វ៉ាន់មូហាម៉ាត់ ណ័រ មះថា** គឺជាការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើកិច្ចព្រមព្រៀងបទឈប់បាញ់ ហើយជាការលើកទឹកចិត្តដល់អំពើបង្កហេតុរបស់យោធាថៃ ទៅជាគោលនយោបាយដែលគាំទ្រដោយស្ថាប័ននីតិប្បញ្ញត្តិថៃ។ រដ្ឋសភានៃប្រទេសទាំងពីរដែលជាស្ថាប័នតំណាងប្រជាពលរដ្ឋ គួរបង្ហាញការសោទរដល់ស្ថានភាពនៅព្រំដែនជាទូទៅដែលមានសភាពស្ងប់ស្ងាត់ល្អ ហើយយើងគួរបន្តធ្វើឱ្យស្ថានភាពនេះរឹតតែប្រសើរឡើង ជាជាងការធ្វើទង្វើដែលបង្កការរាំងស្ទះដល់ការនាំមកវិញនូវសន្តិភាព ស្ថិរភាព និងប្រក្រតីភាពនៃទំនាក់ទំនងរវាងប្រទេសទាំងពីរ ដែលជាអ្វីមិនត្រឹមតែប្រជាជនកម្ពុជាចង់បានប៉ុណ្ណោះទេ ប៉ុន្តែពិភពលោកទាំងមូលក៏ចង់ឃើញផងដែរ ដូចដែលបានស្តែងចេញតាមរយៈការសម្តែងការអបអរសាទរ និងការគាំទ្រចំពោះកិច្ចព្រមព្រៀងបទឈប់បាញ់ និងលទ្ធផលជាវិជ្ជមាននៃកិច្ចប្រជុំវិសាមញ្ញគណៈកម្មាធិការព្រំដែនទូទៅកម្ពុជា-ថៃជាដើម។

**រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា** ចាត់ទុកការថ្លែងបែបនេះថាជាភស្តុតាង ដែលមិនអាចប្រកែកបាននៃអំពើបង្កហេតុ និងការប៉ុនប៉ងដោយចេតនា គិតទុកជាមុន ក្នុងការឈ្លានពានអធិបតេយ្យភាព និងបូរណភាពទឹកដីរបស់កម្ពុជា។ ទង្វើនេះគឺជាការរំលោភបំពានទាំងស្រុងទៅលើកិច្ចព្រមព្រៀងបទឈប់បាញ់ ដែលសម្រេចបាននៅក្នុងកិច្ចប្រជុំពិសេស កាលពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៥ និងស្មារតីនៃកិច្ចប្រជុំវិសាមញ្ញរបស់គណៈកម្មាធិការព្រំដែនទូទៅ (GBC) ដែលបានប្រារព្ធធ្វើឡើងនាថ្ងៃទី៧ ខែសីហា ឆ្នាំ២០២៥។ បន្ថែមពីនេះ ការថ្លែងបែបនេះក៏ជាការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើធម្មនុញ្ញអាស៊ាន ធម្មនុញ្ញអង្គការសហប្រជាជាតិ និងសន្ធិសញ្ញាមិត្តភាព និងសហប្រតិបត្តិការនៅអាស៊ីអាគ្នេយ៍។



វិថីរដ្ឋសភា សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២១៣ ៥៣៥, ២២០ ៦២៨
ទូរសារ: (៨៥៥-២៣) ២២០ ៦២៩ សារអេឡិចត្រូនិច:sg@nac-kh.info គេហទំព័រ: www.nac.org.kh

**រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា** សូមអំពាវនាវដល់សហគមន៍អន្តរជាតិ ជាពិសេសប្រទេសដៃគូ ដែលបានខិតខំប្រឹងប្រែងជួយឱ្យសម្រេចបាននូវបទឈប់បាញ់ដ៏លំបាកមួយនេះ ដោយជួយជំរុញយ៉ាងម៉ឺងម៉ាត់ឱ្យភាគីថៃគោរពកិច្ចព្រមព្រៀងបទឈប់បាញ់ ដោយមិនត្រឹមតែតាមរយៈពាក្យសម្ដីប៉ុណ្ណោះទេ ប៉ុន្តែតាមរយៈសកម្មភាពជាក់ស្ដែង ដោយបញ្ឈប់រាល់អំពើរំលោភបំពានទាំងឡាយ និងរុះរើបន្លាលួសដែលខ្លួនបានលួចដាក់ ចេញឱ្យអស់ជាបន្ទាន់ពីដែនអធិបតេយ្យរបស់កម្ពុជា។

**រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា** សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ **ឯកឧត្តម អាន់វ៉ា អ៊ីប្រាហ៊ីម** នាយករដ្ឋមន្ត្រីនៃប្រទេសម៉ាឡេស៊ី សម្រាប់ការផ្ដួចផ្ដើម សម្របសម្រួល និងធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំសម្រុះសម្រួលរវាងកម្ពុជា-ថៃ និងសូមទទួលស្គាល់នូវតួនាទីគន្លឹះ ដែលបានដើរតួដោយសហរដ្ឋអាមេរិក និងសាធារណរដ្ឋប្រជាមានិតចិន ក៏ដូចជាការគាំទ្រដ៏ស្មោះស្ម័គ្រពីបណ្ដារដ្ឋជាសមាជិកអាស៊ាន ដៃគូសន្ទនា និងប្រទេសជាមិត្តនានាក្នុងតំបន់និងពិភពលោក។ ការលើកទឹកចិត្ត និងការចូលរួមរបស់បណ្ដាប្រទេសទាំងអស់ គឺជាមធ្យោបាយដ៏សំខាន់ ក្នុងការនាំមកនូវដំណោះស្រាយជាវិជ្ជមាន។ ជាពិសេស យើងខ្ញុំសូមកត់សម្គាល់ដោយការកោតសរសើរនូវតួនាទីរបស់ **ឯកឧត្តមប្រធានាធិបតី ដូណាល់ ត្រាំ** នៅក្នុងកិច្ចខិតខំប្រឹងប្រែង ដែលប្ដេជ្ញាចិត្តរួមគ្នាចំពោះសន្តិភាព សន្តិសុខ និងកិច្ចសហប្រតិបត្តិការ ដើម្បីសុខសុវត្ថិភាព អាយុជីវិត និងជីវភាពប្រជាជនកម្ពុជា-ថៃ ក៏ដូចជាដើម្បីប្រក្រតីភាពក្នុងតំបន់ និងនៅក្នុងសហគមន៍អាស៊ានមួយប្រកបដោយស្ថិរភាព និងវិបុលភាព។

**រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា** សូមបញ្ជាក់ពីជំហរដ៏មុតមាំរបស់កម្ពុជាគឺ ស្រឡាញ់សន្តិភាព ការពារសន្តិភាព និងធ្វើជាមិត្តជាមួយគ្រប់បណ្ដាប្រទេសក្នុងតំបន់ និងលើសកលលោក។ កម្ពុជាក៏កំពុងធ្វើការយ៉ាងសកម្ម ដើម្បីលើកកម្ពស់សន្តិភាពតាមរយៈគំនិតផ្ដួចផ្ដើមនានា ដូចជាធម្មនុញ្ញសន្តិភាពសកល ដែលបានផ្ដួចផ្ដើមឡើងដោយ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា ដើម្បីលើកកម្ពស់កិច្ចសន្ទនាប្រកបដោយបរិយាបន្ន កសាងទំនុកចិត្ត ការយល់ដឹងពីគ្នាទៅវិញទៅមក និងកិច្ចសហប្រតិបត្តិការសកលសម្រាប់សន្តិភាព និងវិបុលភាពរួម។

ថ្ងៃចន្ទ ២រោច ខែស្រាពណ៍ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី១១ ខែសីហា ឆ្នាំ២០២៥